Prime Minister of Kingdom of Cambodia
Hun Sen issues a reply letter to the former King Norodom Sihanouk that the latter dispatches on 06 July 2007 the request of Mr. Thach Setha, president of Khmer Kampuchea Krom Community, for His Majesty to conduct investigation into the case of Buddhist monk Tim Sakhorn.

KKC 09/28/2007

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:.....៣៦.....សជណ.កបក

**សូមក្រាបបង្គំទូលថ្វាយ**

**ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះមហាវីរបិតាជាតិខ្មែរ**

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ**

ទូលព្រះបង្គំជាខ្ញុំបានទទួលរួចហើយ នូវព្រះរាជសារលិខិតចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៧ ដែលបានស្នើឱ្យរាជរដ្ឋាភិបាល ពិនិត្យលើសំណើរបស់លោក ថាច់ សេដ្ឋា ប្រធានសមាគមខ្មែរកម្ពុជាក្រោម ករណីចាប់ផ្សឹក និងគំរាមកំហែងមកលើព្រះសង្ឃខ្មែរកំណើតកម្ពុជាក្រោម (ករណីព្រះសង្ឃព្រះនាម ទីម សាខន)។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលថ្វាយព្រះករុណាទ្រង់ព្រះមេត្តាជ្រាបថា ករណីនេះរាជរដ្ឋាភិបាលបានចាត់ឱ្យមានការស្រាវជ្រាវដល់ទីកន្លែងទទួលបានលទ្ធផលដូចខាងក្រោម:

ព្រះចៅអធិការវត្តបោភ្ជណារាម ព្រះនាម ទីម សាខន សញ្ជាតិខ្មែរកម្ពុជាក្រោម ស្រុកកំណើតភូមិខ្នា-គ្របើម ឃុំបាជុក ស្រុកស្វាយទង ខេត្តអាងយ៉ាង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម គង់នៅវត្តបោភ្ជណារាម (វត្តភ្នំដិនខាងជើង) ស្ថិតនៅភូមិផ្សារ ឃុំភ្នំដិន ស្រុកគីរីវង្ស ខេត្តតាកែវ បានយកវត្តអារាមធ្វើជាកន្លែងចែកចាយព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលក្នុងមួយក្បាលៗមានចំនួនពី១៤ ទៅ ២០ទំព័រ មានខ្លឹមសារឃោសនាញុះញង់ក្នុងគោលបំណងបង្កជម្លោះរវាងកម្ពុជា-វៀតណាម។ ព្រះសង្ឃ ទីម សាខន មានចិត្តមានះមិនចូលរួមប្រជុំនិងធ្វើអ្វីៗក្នុងវត្តគ្មានច្បាប់អនុញ្ញាតត្រឹមត្រូវ ដូចជា បង្ហូតទង់ដែលមានទ្រង់ទ្រាយស្រដៀងនឹងសញ្ញាសម្គាល់លើព្រឹត្តិបត្រសហព័ន្ធខ្មែរកម្ពុជាក្រោម សាងសង់សំណង់រឹងមួយខ្នងជាប់នឹងរបងវត្តខាងក្នុង បំបួសព្រះសង្ឃមួយចំនួនមកពីបឹងសាឡាងដោយឥតច្បាប់ ទាក់ទាញព្រះសង្ឃនិងឧបាសិកាមួយចំនួនធំដោយជ្រកក្រោមសហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្រៅប្រទេស។ សកម្មភាពទាំងអស់នេះ ធ្វើឱ្យព្រះសង្ឃក្នុងវត្តមិនពេញចិត្ត ព្រះសង្ឃមួយចំនួនលាចាកសិក្ខាបទ ព្រះសង្ឃខ្លះសុំទៅរៀនសូត្រគង់នៅវត្តផ្សេង ហើយព្រះសង្ឃចំនួន ០៧ អង្គ ឆាយា ព្រះសង្ឃដីកាបិងច្បាស់លាស់។

ព្រះសង្ឃអង្គនេះ និងក្រុមបក្សពួក បានធ្វើបាតុកម្មចំនួន ០២លើក ប្រឆាំងនឹងមិត្តភាពកម្ពុជា-វៀតណាម រហូតឈានដល់ធ្វើការប្រឆាំងជាមួយនឹងសមណសិស្ស សមណនិស្សិត អ្នកបួសក្នុងសាសនា ដោយប្រើពូថៅ និងដំបងដេញកាប់ព្រះសង្ឃចំនួន ២០អង្គ ដែលជាក្រុមសម្របសម្រួលបណ្តាលឱ្យរងរបួសចំនួន ០៤ អង្គ។

ក្រោយពីពិនិត្យឃើញនូវសកម្មភាពមិនប្រក្រតីរបស់ព្រះសង្ឃ ទឹម សាខន សម្ដេចអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស បានបើកកិច្ចប្រជុំដែលមានការចូលរួមពីព្រះសង្ឃគ្រប់ជាន់ថ្នាក់ចំនួន ១០ អង្គ ដើម្បីពិភាក្សាវិនិច្ឆ័យទោស និងបានឯកភាពត្រូវផ្សឹកព្រះភិក្ខុ ទឹម សាខន ចេញពីបព្វជិតដោយមូលហេតុព្រះសង្ឃអង្គនេះប្រព្រឹត្តធ្ងន់ធ្ងរទៅនឹងធម្មវិន័យរបស់ព្រះសង្ឃ ។

បន្ទាប់ពីបានផ្សឹកកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧រួចមក អាជ្ញាធរស្រុក មន្ទីរធម្មការនិងសាសនាស្រុក ក្រុមប្រឹក្សាឃុំ អាចារ្យគណៈកម្មការវត្ត បានធ្វើការពិនិត្យក្នុងកុដិអតីតចៅអធិការ ទឹម សាខន ដោយមានដីកាបង្គាប់ឱ្យឆែកឆេរ របស់តុលាការខេត្តតាកែវ បានរកឃើញវត្ថុតាងមួយចំនួនដូចជា : កាំបិតសាំងតីម វីស៊ីឌីអាសអាភាស និងឃើញមនុស្សស្រី ០២ នាក់ នៅក្នុងកុដិ ហើយក៏បានពិនិត្យឃើញលិខិតស្នើសុំមួយច្បាប់ របស់លោក ទឹម សាខន ស្នើសុំត្រឡប់ទៅស្រុកកំណើតវិញ (ប្រទេសវៀតណាម) ផងដែរ។

តាមព័ត៌មានអ្នកនាំពាក្យស្ថានទូតវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជាបានប្រកាសថា លោក ទឹម សាខន កំពុងត្រូវឃុំខ្លួនដោយអាជ្ញាធរនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហើយមូលហេតុពិតប្រាកដនៃការឃុំខ្លួននេះ ហើយពុំដឹងច្បាស់លាស់ទេ ។

សេចក្ដីដូចបានទូលថ្វាយខាងលើនេះ សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ ទ្រង់ព្រះមេត្តាជ្រាប ដ៏ខ្ពង់ខ្ពស់បំផុត ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាតយកឱកាសនេះ សូមថ្វាយព្រះពរមហាប្រសើរ ហើយសូមទ្រង់គង់នៅ ប្រកបដោយព្រះបរមសុខជារៀងរហូតតទៅ ។

សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវភក្ដីភាពដ៏ស្មោះស្ម័គ្រ ពីទូលព្រះបង្គំជាខ្ញុំ ។ ១៨

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ កញ្ញា ឆ្នាំ ២០០៧

ហ៊ុន សែន

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

Prime Minister of Kingdom of Cambodia
Hun Sen issues a reply letter to the former King
Norodom Sihanouk that the latter dispatches
on 06 July 2007 the request of Mr. Thach Setha,
president of Khmer Kampuchea Krom
Community, for His Majesty to conduct
investigation into the case of Buddhist monk
Tim Sakhorn.
KKC 09/28/2007